ការបង្ហាញអំពីប្រល័យពូជសាសន៍ : គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ
កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# ការបង្រៀនស្តីពីប្រទេសកម្ពុជាដល់ប្រជាជនចម្រុះពូជសាសន៍ នៅវិទ្យាល័យក្នុងសហរដ្ឋអាមេរិក

**មីរៀម ម៉រហ្គិនស្ទើន**

## សេចក្តីផ្តើម

ដោយក្រឡេកមើលត្រឡប់ទៅក្រោយ ខ្ញុំកត់សម្គាល់ឃើញថា ខ្ញុំកំពុងបង្រៀនប្រជាជនកម្ពុជាពេញមួយអាជីពរបស់ខ្ញុំ ។ បទពិសោធន៍ទីមួយរបស់ខ្ញុំចំពោះការងារដំបូងនៅក្នុងមជ្ឈមណ្ឌលអប់រំមនុស្សពេញវ័យនៅឆេនិតាឌី Schenectady ក្នុងទីក្រុងញូវយ៉ក New York នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ។ ជនភៀសខ្លួនកម្ពុជាម្នាក់បានប្រាប់សិស្សទាំងអស់នៅក្នុងថ្នាក់រៀនរបស់យើងអំពីបទពិសោធន៍របស់គាត់ក្នុងនាមជាក្មេងម្នាក់ ដែលធំធាត់ក្រោមរបបខ្មែរក្រហម ។ ក្នុងការប៉ុនប៉ងរក្សាកូនស្រីរបស់ខ្លួនឲ្យមានសុវត្ថិភាព ម្តាយរបស់នាងបានប្រាប់ក្មេងស្រីនេះមិនឲ្យនិយាយ ហេតុដូច្នេះហើយនាងក៏ក្លាយជាមនុស្សគមិនអាចនិយាយបានអស់រយៈពេលបីបួនឆ្នាំ ។ សម្រាប់សិស្សកម្ពុជារូបនេះ ការនិយាយភាសាអង់គ្លេស ទោះបីជាប្រឈមមុខនឹងឧបសគ្គក៏ដោយ ក៏ផ្តល់ឲ្យនាងនូវឱកាសដើម្បីចែករំលែកវិបត្តិផ្លូវចិត្តរបស់នាងនៅក្នុងបរិស្ថានមួយប្រកបដោយសុវត្ថិភាព ។ នៅពេលនោះ ខ្ញុំផ្ទាល់គឺជាស្ត្រីវ័យក្មេងមួយរូប ហើយខ្ញុំបានដឹងអំពីប្រទេសកម្ពុជា និងអ្វីដែលបានកើតឡើងនៅទីនោះមានតែតិចតួចប៉ុណ្ណោះ ។ ប៉ុន្តែជាច្រើនឆ្នាំក្រោយមក ខ្ញុំនៅតែចងចាំរឿងរបស់នាងនិងកន្លែងដែលយើងអង្គុយនៅពេលនាងប្រាប់យើងអំពីបទពិសោធន៍របស់នាង ។

កាលពី១៨ឆ្នាំកន្លងទៅ ខ្ញុំបង្រៀននៅវិទ្យាល័យឡូវែល (Lowell) ក្នុងទីក្រុងឡូវែល នៃរដ្ឋម៉ាសាឈូសេតស៍ (Massachusetts) ។ វិទ្យាល័យឡូវែលមានសិស្សប្រហែល៣ពាន់៤រយនាក់ ហើយគឺជាវិទ្យាល័យធំជាងគេលំដាប់ទី២នៅក្នុងរដ្ឋនេះ ។ វិទ្យាល័យនេះក៏ជាវិទ្យាល័យមួយក្នុងចំណោមវិទ្យាល័យ ដែលមានសិស្សចម្រុះពូជសាសន៍ច្រើនជាងគេបំផុត នៅក្នុងរដ្ឋខមមិនវែល

(Commonwealth) ដោយរួមមាន៤០ភាសាដែលត្រូវបាននិយាយនៅក្នុងផ្ទះរបស់សិស្ស ។ ទីក្រុងឡូវែលមានសហគមន៍ជនជាតិខ្មែរច្រើនជាងគេលំដាប់ទី២នៅក្នុងសហរដ្ឋអាមេរិក ។ យោងតាមនាយកដ្ឋានអប់រំ ចំនួនសិស្សប្រហែល២៩ភាគរយគឺជាជនជាតិអាស៊ី ហើយចំនួនភាគច្រើនលើសលប់នៃក្រុមនេះគឺជាអាណិកជនខ្មែរសញ្ជាតិអាមេរិកាំង ។ បន្ថែមលើសនេះទៀត វិទ្យាល័យនេះមានសិស្សអន្តោប្រវេសន៍ជាច្រើន ហេតុដូចនេះ ទើបមានកម្មវិធីសិក្សាភាសាអង់គ្លេសជាភាសាទីពីរ ។ អ្នកចំណូលថ្មីជាច្រើនគឺមកពីប្រទេសកម្ពុជា ។ អ្នកផ្សេងទៀតមកពីសាធារណរដ្ឋដូមីនិកាំង (Dominican Republic) ប្រទេសលីបេរីយ៉ា (Liberia) និងប្រទេសប្រេស៊ីល (Brazil) ។ ៦០ភាគរយនៃក្រុមគ្រួសារសិស្សទាំងនេះត្រូវបានចាត់ទុកថាមានចំណូលទាប ។

## វគ្គសិក្សាថ្មីមួយ : ប្រទេសកម្ពុជា : វប្បធម៌និងជម្លោះ

ពីឆ្នាំកន្លងមក ខ្ញុំបានស្នើទៅប្រធាននាយកដ្ឋានរបស់ខ្ញុំថា ខ្ញុំបង្រៀនវគ្គសិក្សាស្តីពីប្រទេសកម្ពុជា ។ ខ្ញុំធ្លាប់បានបង្រៀនរួចហើយនូវវគ្គសិក្សារបស់អង្គការ *ការប្រឈមមុខនឹងប្រវត្តិសាស្ត្រនិងខ្លួនឯង* ដែលជាកម្មវិធីសិក្សា ដែលទទួលស្គាល់ជាលក្ខណៈជាតិដើម្បីបង្រៀនអំពីយុត្តិធម៌សង្គមនិងអំពើប្រល័យពូជសាសន៍ ហើយជាពិសេសគឺហូឡូខូសត៍ (Holocaust) ។ បទពិសោធន៍បង្រៀនរបស់ខ្ញុំអំពីហូឡូខូសត៍ ធ្វើឲ្យខ្ញុំពិចារណានូវលទ្ធភាពទៅលើវគ្គសិក្សាអំពីប្រទេសកម្ពុជា ។ ដោយរួមមានសិស្សចំនួនជិត៣០ភាគរយដែលមានដើមកំណើតជាជនជាតិខ្មែរ វគ្គសិក្សាបែបនេះហាក់ដូចជាមានភាពសមរម្យនិងចាំបាច់ ។ វិទ្យាល័យឡូវែលមានថ្នាក់ភាសាខ្មែរដែលបង្រៀនដោយគ្រូជនជាតិខ្មែរសញ្ជាតិអាមេរិកកាំង ។ ខ្ញុំបានដឹងថា វគ្គសិក្សាស្តីពីប្រវត្តិសាស្ត្រនិងវប្បធម៌របស់ប្រទេសកម្ពុជាគួរតែខុសគ្នា វាអាចទាក់ទាញតំណាងគំរូនៃអត្តភាពសិស្សប្រសិនបើវាទទួលបានជោគជ័យ ។ ហើយប្រសិនបើវាអាចទាក់ទាញក្រុមសិស្សចម្រុះនេះបាន ខ្ញុំចាំបាច់ត្រូវស្វែងរកមធ្យោបាយដើម្បីបញ្ចូលសិស្សទាំងអស់ និងធ្វើឲ្យពួកគេចាប់អារម្មណ៍ពិតប្រាកដចំពោះប្រទេសនិងវប្បធម៌ ដែលពួកគេបានដឹងតិចតួច ។

## បញ្ហាពីខាងក្រៅជុំវិញវគ្គសិក្សានេះ

បញ្ហាមួយចំនួន ដែលកើតចេញពីគ្រូបង្រៀននិងបុគ្គលិកអំពីការផ្តល់ឲ្យនូវវគ្គសិក្សានេះ ។ បញ្ហាទី១គឺថា គ្រូជាច្រើន (អ្នកផ្តល់ដំបូន្មានទៅលើការណែនាំនិងបុគ្គលិកដទៃទៀត) ជឿថា នេះគឺជាថ្នាក់រៀនដែលមានតែសិស្សខ្មែរសញ្ជាតិអាមេរិកកាំងទេ ដែលអាចទទួលបានផលប្រយោជន៍ ។ ខ្ញុំចាំបាច់ត្រូវតែបំបាត់រឿងដែលមិនពិតនេះ ចេញពីក្នុងចំណោមអ្នកផ្តល់ដំបូន្មានទៅលើការណែនាំជាពិសេស ក្នុងចំណោមបុគ្គលិកដទៃផ្សេងទៀត ដែលជឿថាវគ្គសិក្សានេះគឺសម្រាប់តែក្មេងជំទង់

ជនជាតិខ្មែរសញ្ជាតិអាមេរិកាំង និងដែលមានសារសំខាន់ចំពោះតែក្មេងជំទង់ជនជាតិខ្មែរសញ្ជាតិអាមេរិកកាំងប៉ុណ្ណោះ ។ នៅក្នុងន័យនេះ វាបានជួយដល់ខ្ញុំដែលមិនមែនជាជនជាតិខ្មែរ ។ ខ្ញុំអាចពន្យល់បានថា ថ្នាក់រៀននេះមិនមែនស្តីតែពីប្រទេសកម្ពុជាទេ ប៉ុន្តែផ្ទៃរឿងដែលគ្របដណ្តប់នៅក្នុងថ្នាក់នឹងមានលក្ខណៈជាសកល ទូទាំងពិភពលោក និងពាក់ព័ន្ធគ្នា ។ ម្យ៉ាងវិញទៀត មានការមិនទុកចិត្តគ្នា រវាងបុគ្គលិកដែលជាជនជាតិខ្មែរនិងបុគ្គលិកដែលមិនជាជនជាតិខ្មែរ ហើយដែលបង្រៀនវគ្គសិក្សានេះ ។ ដោយផ្អែកលើទស្សនៈរបស់បុគ្គលម្នាក់ៗ ខ្ញុំបាននិយាយជាមួយគ្រូបង្រៀនភាសាខ្មែរនិងបុគ្គលិកជំនួយដទៃទៀត អំពីប្រវត្តិរបស់ខ្ញុំក្នុងការបង្រៀនអំពីហូឡូខូសត៍ និងប្រវត្តិរៀនសូត្ររបស់ខ្ញុំ ដែលជាអ្នកអប់រំចេញមកពីវគ្គសិក្សាទៅលើការប្រឈមមុខនឹងប្រវត្តិសាស្ត្រនិងខ្លួនឯង ។ ខ្ញុំបានពន្យល់ថា ខ្ញុំមិនមែនជាអ្នកជំនាញទៅលើប្រវត្តិសាស្ត្រកម្ពុជាទេ ខ្ញុំមិននិយាយភាសាខ្មែរ ហើយខ្ញុំដឹងអំពីកម្រិតព្រំដែនរបស់ខ្ញុំទៅលើប្រវត្តិសាស្ត្រនេះ ។ ជំនួសមកវិញ ជំនាញរបស់ខ្ញុំគឺខាងគរុកោសល្យនិងការផ្តល់ការបង្ហាត់បង្រៀន ។ ខ្ញុំបានពន្យល់បន្ថែមថា វគ្គសិក្សាអំពីហូឡូខូសត៍ត្រូវបានបង្រៀននៅជុំវិញពិភពលោក ហើយដោយគ្មានការរំពឹងគិតទុកថា គ្រូបង្រៀនគួរតែជាជនជាតិជ្វីហ្វឡើយ ។ ការពិត វាចាំបាច់ដែលថា ការសម្លាប់ជារួមនិងអំពើប្រល័យពូជសាសន៍ មិនត្រូវបានមើលឃើញថាជាបញ្ហារបស់“ពួកគេ” ទេ ប៉ុន្តែជំនួសមកវិញ វាគឺជាបញ្ហាដែលមានការពាក់ព័ន្ធជាសាកលសម្រាប់មនុស្សទាំងអស់ ។ សហសេវិករបស់ខ្ញុំម្នាក់ដែលរស់នៅក្រោមរបបខ្មែរក្រហមបានប្រាប់ខ្ញុំថា គាត់គ្រាន់តែចង់ឲ្យមានការធានាឡើងវិញថា ខ្ញុំនឹងមិនបង្រួមប្រទេសកម្ពុជាឲ្យនៅត្រឹមប្រវត្តិសាស្ត្រស្តីពីអំពើប្រល័យពូជសាសន៍នោះទេ ប៉ុន្តែត្រូវមើលរាល់ទិដ្ឋភាពផ្សេងៗ អំពីវប្បធម៌និងប្រវត្តិសាស្ត្រខ្មែរដែលមានលក្ខណៈសម្បូរបែបនិងរស់រវើក ។ បុគ្គលិកខ្មែរជាច្រើនក្លាយជាអ្នកជំទាស់ចំពោះវគ្គសិក្សាហើយតាំងខ្លួនជាវាគ្មិននៅក្នុងថ្នាក់រៀនរបស់ខ្ញុំ ។ បញ្ហាទី៣ ដែលកើតឡើងហើយដែលខ្ញុំនៅតែតស៊ូនៅឡើយគឺភាពស្មើគ្នា ។ អ្នកខ្លះជំទាស់ថា ប្រសិនបើសាលារៀនផ្តល់វគ្គសិក្សាស្តីពីប្រទេសកម្ពុជា តើមិនគួរមានវគ្គសិក្សាដែលផ្តល់ឲ្យស្តីពីទ្វីបអាហ្វ្រិក ឬក៏បទពិសោធន៍របស់ជនជាតិអាហ្វ្រិកសញ្ជាតិអាមេរិកាំង ឬក៏សាធារណរដ្ឋឆ្ងូមីនិកាំងទេឬ? នៅក្នុងន័យនេះ ខ្ញុំមើលឃើញថា ថ្នាក់រៀននេះជាការចាប់ផ្តើមទៅលើកម្មវិធីសិក្សាពីសង្គម ដែលមានការកែប្រែជាលក្ខណៈសាកល ដែលជាកម្មវិធីសិក្សាក្នុងសតវត្សរ៍ទី២១ នឹងរួមបញ្ចូលភាពចម្រុះដែលបង្កើតឡើងបានជាសហរដ្ឋអាមេរិក ។

## ការពិនិត្យមើលទៅលើកម្មវិធីសិក្សា

ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបត្រួសៗទៅលើកម្មវិធីសិក្សា ដែលខ្ញុំបានបង្កើតសម្រាប់ថ្នាក់រៀន ។ កម្មវិធីនេះកំពុងតែត្រូវបានសាកល្បងនិងកែសម្រួលនៅឡើយ ។ វាផ្អែកយ៉ាងទូលាយទៅលើកម្មវិធីសិក្សារបស់អង្គការ ការប្រឈមមុខនឹងប្រវត្តិសាស្ត្រនិងខ្លួនឯង។

◆អត្តសញ្ញាណ ៖ រួមមានគារាងសម្រាប់សម្គាល់អត្តសញ្ញាណ ប្រភពកំណើតអំពីឈ្មោះរបស់សិស្ស ការអានស្ដីពីអត្តសញ្ញាណបានមកពីវគ្គសិក្សារបស់អង្គការ ការប្រឈមមុខនឹងប្រវត្តិសាស្ត្រនិងខ្លួនឯង ការដកស្រង់ចេញពីអក្សរសិល្ប៍ ពត៌មានស្ដីពីអ្នកដទៃ អត្តសញ្ញាណជាតិ ។

◆ការបង្កើតក្រុម/ការកសាងជាតិ ៖ ផលប៉ះពាល់នៃការប្រកាន់ទៅលើក្រុមជាក់លាក់មួយ និងបុរេនិច្ឆ័យ អំណាចរបស់ពាក្យបន្តក្បត់ ខ្លួនរបស់យើងនិងអ្នកដទៃ ការកសាងជាតិ អាណានិគមនិយម/ចក្រពត្តិនិយម ការអភិវឌ្ឍមនោគមន៍នយោបាយ ។

◆ប្រជាជនខ្មែរ ៖ តើពួកគេមកពីណា? អ្វីទៅជាវប្បធម៌របស់ប្រជាជនខ្មែរ? អរិយធម៌ដំបូង រួមមានសម័យអង្គរ (ការរុងរឿងនិងការធ្លាក់ចុះ) ភូមិសាស្ត្ររួមមានការផ្លាស់ប្ដូរដែនទី(គម្រោង) អាស៊ីអាគ្នេយ៍ អាស៊ី សេចក្ដីណែនាំអំពីព្រះពុទ្ធសាសនា ។

◆អាណានិគមបារាំង ៖ រួមមានព័ត៌មានស្ដីពីអំឡុងពេលរវាងសម័យអង្គរ និងការចូលមករបស់បារាំងក្នុងប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ និងអាណានិគមនិយម ។

◆សង្គ្រាមវៀតណាម ៖ កុម្មុយនីស្ត, ហូ ជីមិញ, ការពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក ការទម្លាក់គ្រាប់បែកទៅលើប្រទេសកម្ពុជា សីហនុ, លន់ នល់, សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា ។

◆ប៉ុល ពត និងការកើតឡើងនៃរបបកម្ពុជាប្រជាធិបតេយ្យ ៖ ការរួបរួមអំណាច មនោគមន៍វិជ្ជា ប្រភពគំនិត (ពីខាងក្នុងចំពោះកម្ពុជា និងពីខាងក្រៅទៅចំពោះម៉ៅ/ប្រទេសចិន) ។

◆អំពើប្រល័យពូជសាសន៍ (ប្រល័យពូជសាសន៍ខ្លួនឯង) ៖

ក. ចំនួនប្រជាជនដែលត្រូវបានដៅទុក

ខ. អ្វីដែលបានកើតឡើង រួមមានរឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិត ការដកស្រង់ពីកំណត់ប្រវត្តិរឿងរ៉ាវ ខ្សែភាពយន្តឯកសារវាលពិឃាត ខ្សែភាពយន្តឯកសារឆ្នាំទី១ ខ្សែភាពឯកសារស្ដីពីគុកទួលស្លែង និង ខ្សែភាពយន្តរឿងអ្នកជិះខ្យល់ ។

គ. ការឆ្លើយតបរបស់សហរដ្ឋអាមេរិក/ការឆ្លើយតបរបស់អន្តរជាតិ

◆បន្ទាប់ពីរបបប្រល័យពូជសាសន៍ ៖ ជំរំជនភៀសខ្លួន ការចាកចេញពីប្រទេសកម្ពុជា ជនភៀសខ្លួននៅក្នុងប្រទេសអាមេរិក ប្រទេសកម្ពុជាបច្ចុប្បន្ន

◆ទីក្រុងឡូវែល ៖ ទីក្រុងជនអន្តោប្រវេសន៍ មនុស្សវ័យក្មេង/ឪពុកម្ដាយអន្តោប្រវេសន៍ ភាពមិនប្រក្រតីនៃការតានតឹងក្រោយពីការប៉ះទង្គិចផ្លូវចិត្ត ក្រុមជនអន្ធពាល ការមិនចូល

ក្នុងសង្គមរវាងឪពុកម្ដាយនិងកូន ការតស៊ូខាងសេដ្ឋកិច្ច (ជាទូទៅចំពោះជនអន្តោប្រវេសន៍នៅក្នុងទីក្រុង)

◆យុត្តិធម៌បន្ទាប់ពីរបបប្រល័យពូជសាសន៍ : ការក្រឡេកមើលទៅលើសាលាក្តី (ខ្មែរក្រហម) សាលាក្ដីនូរឹមបឺក គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង ការរស់ឡើងវិញនូវវប្បធម៌ខ្មែរនៅសហរដ្ឋអាមេរិកនិងប្រទេសកម្ពុជា (អាន ឈនផុន, របាំ វិហារព្រះពុទ្ធសាសនា)

◆គម្រោងកម្រិតកំពូល (អាចជាប្រវត្តិសាស្ត្រតាមរយៈការសួរនាំ ប្រវត្តិគ្រួសារ ប្រវត្តិសមាជិកសហគមន៍ ការពិភាក្សា)

ជាថ្មីម្តងទៀត នេះគឺជាការងារកំពុងដំណើរការនៅឡើយ ។ វាលំបាកក្នុងការបញ្ចូលអ្វីៗទាំងអស់ទៅក្នុងនេះ ប៉ុន្តែវាសំខាន់ដែលមិនត្រូវភ្លេចបញ្ចូលអ្វីៗទាំងអស់ដែរ ។ វគ្គសិក្សានេះត្រូវបានរៀបចំឡើងសម្រាប់វិទ្យាល័យអាមេរិកាំងនិងសិស្សវិទ្យាល័យអាមេរិកាំង ។ វាចាំបាច់ត្រូវមានការអំពាវនាវទូលំទូលាយមួយ ។ ឧទាហរណ៍ នៅពេលថ្នាក់រៀនសិក្សាអំពីគុកទួលស្លែង យើងចំណាយពេលមួយផ្នែកធំនៃថ្នាក់រៀន ដើម្បីអានអត្ថបទអំពីការសម្រេចចិត្តថ្មីៗដោយរដ្ឋបាលប៊ូស និងអូបាម៉ាទាក់ទិននឹងវិធីសាស្ត្រធ្វើទារុណកម្មដោយរដ្ឋាភិបាលអាមេរិក ។ នៅពេលថ្នាក់រៀន សិក្សាពីអង្គរវត្តសិស្សត្រូវបានផ្តល់ឲ្យនូវរូបភាពបីបួន និងត្រូវបានស្នើឲ្យវិភាគរូបភាពទាំងនោះដើម្បីបង្កើតជាសម្មតិកម្មអំពីវប្បធម៌សម័យអង្គរ ។

## ថ្នាក់រៀននៅក្នុងសតវត្សរ៍ទី២១

ដើម្បីបង្កើតថ្នាក់រៀនប្រកបដោយភាពស្វាហាប់ និងរៀបចំសិស្សសម្រាប់ការអប់រំនិងការងារបន្ថែមទៀត វាចាំបាច់ក្នុងការបញ្ចូលជំនាញនិងផ្ទៃរឿងខាងក្រោមទៅក្នុងគម្រោងមេរៀន : សម្រាប់ព័ត៌មានបន្ថែមស្តីពីប្រធានបទនេះ អ្នកអាចរកមើលបានតាមរយៈគេហទំព័រ http://21stcenturyskills.org

◆ការយល់ដឹងជាសាកល

◆ការច្នៃប្រឌិតនិងការស្រមៃ

◆ ការគិតបែបវិភាគនិងការដោះស្រាយបញ្ហា

◆ ការងារទំនាក់ទំនងនិងការងារសហការ

◆ ការផ្តួចផ្តើមគំនិតនិងការដឹកនាំផ្ទាល់ខ្លួន

◆ ជំនាញខាងសង្គមនិងវប្បធម៌ចម្រុះ

◆ ភាពជាអ្នកដឹកនាំនិងការទទួលខុសត្រូវ

◆ ភាពជាពលរដ្ឋល្អនិងការចូលរួមជាលក្ខណៈប្រជាធិបតេយ្យ

**ធនធាន**

ធនធាននៅសាលាមានកម្រិត ហើយយើងមិនមានថវិកាសម្រាប់ទិញសម្ភារឬសៀវភៅ ទេ ។ ខ្ញុំត្រូវមានការច្នៃប្រឌិតក្នុងការវែអង្គាសវិភាគទានដើម្បីទិញសៀវភៅនិងសម្ភារៈផ្សេងៗ ។

*សៀវភៅសិក្សា ៖*

ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយ ឌី ខាំបូលី

ខ្ញុំក៏ប្រើគេហទំព័រផ្ទាល់ខ្លួនរបស់ខ្ញុំ ជាប្រភពពត៌មានចម្បងសម្រាប់សិស្សរបស់ខ្ញុំ ។ នៅក្នុងគេហទំព័ររបស់ខ្ញុំ ខ្ញុំរួមបញ្ចូលព័ត៌មានអំពីការធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា ប្រវត្តិសាស្ត្រកម្ពុជា និងវប្បធម៌នៃប្រទេសកម្ពុជា ។

*កំណត់ប្រវត្តិ ៖*

មុនដំបូងខ្មែរក្រហមសម្លាប់ប៉ាខ្ញុំ ដោយ លឿង អ៊ុង

រស់រានពីវាលពិឃាត ដោយ ហាំង ង៉ោ

*ភាពយន្តឯកសារ ៖*

ខ្សែភាពយន្តឯកសាររឿងវាលពិឃាត, ខ្សែភាពយន្តឯកសាររឿងមន្ទីរស-២១, ខ្សែភាពយន្តរឿងអ្នកជុំខ្ញុំយ, ខ្សែភាពយន្តរឿងរបាំស្វា, ខ្សែភាពយន្តរឿងការធ្វើទារុណកម្ម, ខ្សែភាពយន្តរឿងឆ្នាំទី១, ខ្សែភាពយន្តរឿងវៀតណាម ៖ ប្រវត្តិទូរទស្សន៍, ទារកក្នុងឆ្នាំថ្មី, ខ្សែភាពយន្តរឿងនៅក្នុងស្រមោលអង្គរវត្ត ។

*វាគ្មិន ៖*

វាគ្មិនជាច្រើនមកពីសហគមន៍ខ្មែរទីក្រុងឡូវែល ។ លើសពីនេះទៀត ខ្ញុំមានសំណាងណាស់ដែលបានឆ្លើយឆ្លងអ៊ីម៉ែលជាមួយសាស្ត្រាចារ្យ ដេវីដ ឆេនល័រ ។ បន្ទាប់ពីបង្រៀន៥ថ្នាក់ក្នុងមួយ ថ្ងៃ ៥ថ្ងៃក្នុងមួយសប្តាហ៍ និងធ្វើគម្រោងសិក្សា ព្រមទាំងរៀបចំសម្រាប់ថ្នាក់រៀនរៀងរាល់ល្ងាច រួចមកខ្ញុំក៏ទទួលបានចម្លើយយ៉ាងរហ័សចំពោះសំណួររបស់ខ្ញុំពីបណ្ឌិត ឆេនល័រ ។ លោកជួយខ្ញុំបានយ៉ាងច្រើន ។ សិស្សរបស់ខ្ញុំនិងខ្ញុំគឺជាអ្នកសិក្សាទាំងអស់គ្នា ។ នៅក្នុងពេលដែលពិភពលោកកាន់តែមានភាពស្មុគស្មាញ យើងធ្វើដំណើរតាមរយៈព័ត៌មានច្រើនសន្ធឹកសន្ធាប់ វិធីសាស្ត្រទាក់ទងគ្នាថ្មីៗ និងបច្ចេកវិជ្ជាដែលមានការផ្លាស់យ៉ាងឆាប់រហ័ស ។ យើងក្រឡេកមើលទៅអតីតកាល

ដើម្បីយល់ដឹងការណែនាំនិងការអត់ធ្មត់ ដែលអាចជួយឲ្យយើងក្រសោបយកអនាគត ដែលប្រកបដោយភាពយុត្តិធម៌និងភាពអាណិតស្រឡាញ់ ។

«ចប់»

ប្រែសម្រួលដោយ សូ ហារីណា
ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩